**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អគ្គនាយកដ្ឋានពន្ធដារ**
**នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ......៩៤៧......អពដ

រាជធានីភ្នំពេញ, ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១២

# សេចក្តីជូនដំណឹង

កាលបរិច្ឆេទកំណត់ចុងក្រោយនៃការប្រកាសបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ២០១២ នៅសល់តែ០៥ថ្ងៃទៀតនឹងត្រូវផុតកំណត់ ។ ក្នុងពេលបច្ចុប្បន្ននេះអគ្គនាយកដ្ឋាន-ពន្ធដារសង្កេតឃើញថា មានម្ចាស់យានយន្តតិចតួចប៉ុណ្ណោះ ប្រមាណពី ១០ ទៅ ២០ រូប ដែលបានមកប្រកាសបង់ពន្ធតាមទីតាំងបង់ពន្ធនីមួយៗក្នុងមួយថ្ងៃៗ ។

អាស្រ័យហេតុនេះអគ្គនាយកដ្ឋានពន្ធដារសូមរំលឹក និងអំពាវនាវ ជាថ្មីចំពោះលោក លោកស្រីជាម្ចាស់យានយន្តទាំងអស់ មេត្តារួតរះអញ្ជើញមកបង់ពន្ធ ចៀសវាងប្រជ្រៀតគ្នានៅថ្ងៃផុតកំណត់ ដែលនាំឱ្យមានការកកកុញ និងអាចនាំឱ្យមានបាតុភាពអសកម្មជាយថាហេតុ អំពីការផ្តល់សេវា របស់មន្ត្រីពន្ធដារ ។

អគ្គនាយកដ្ឋានពន្ធដារ សង្ឃឹមយ៉ាងមុតមាំថា លោក លោកស្រី ដែលជាម្ចាស់យានជំនិះគ្រប់ប្រភេទពិតជានឹងយកចិត្តទុកដាក់ និងរួតរះបំពេញកាតព្វកិច្ចបង់ពន្ធតាមការអំពាវនាវនេះ ជាពុំខាន ។

**អគ្គនាយកដ្ឋានពន្ធដារ**

**ចម្លងជូនៈ**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- គ្រប់សាលាខេត្ត-រាជធានី
- គ្រប់សាខាពន្ធដារខេត្ត-ខណ្ឌ "ដើម្បីជូនជ្រាបជាព័ត៌មាន"
- ឯកសារ-កាលប្បវត្តិ

អាគារកែងមហាវិថី សហព័ន្ធរុស្ស៊ី (១១០) និងម៉ៅសេទុង (២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
CORNER RUSSIAN FEDERATION & MAO TSETONG BLVD. TOEK LAAK 1, TOUL KAUK, PHNOM PHNOM PENH
ទូរស័ព្ទ: (៨៥៥) ២៣ ៨៨៦ ៧០៨ / ទូរសារ: (៨៥៥) ២៣ ៨៨៦ ៧០០
Phone: (855) 23 886 708 / Fax: (855) 23 886 700